## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្តមណ្ឌលគិរី មកជា ស្រុក សែនមនោរម្យ ដែលមាន ទីតាំងរដ្ឋបាលសាលា ស្រុក នៅភូមិចំបក់ ឃុំ ស្ពានមានជ័យ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួន បួន ចំណុះទីរួមខេត្តមកជា ឃុំចំនួន បួន ចំណុះស្រុកសែនមនោរម្យ គឺ :

-សង្កាត់ទី ១ មកជា ឃុំ មនោរម្យ

-សង្កាត់ទី ២ មកជា ឃុំ សុខដុម

-សង្កាត់ទី ៣ មកជា ឃុំ ស្ពានមានជ័យ

-សង្កាត់ទី ៤ មកជា ឃុំ រមនា

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ២០ អនក្រ
# ស្តីពីការប្តូរឈ្មោះទីរួមខេត្ត
# សង្កាត់ ក្នុងខេត្តព្រះវិហារ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

www.pheakdeylaw.com

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះ ទីរួមខេត្ត របស់ខេត្ត ព្រះវិហារ មកជាស្រុកត្បែងមានជ័យ ដែលមានទីតាំងរដ្ឋបាល សាលាស្រុក នៅភូមិការកិច្ច ឃុំ ប៉ាលហាល ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះ សង្កាត់ មិត្តភាព ចំណុះទីរួមខេត្ត មកជា ឃុំកំពង់ប្រណាក ចំណុះស្រុកត្បែងមានជ័យ ។

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្ត ព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ២១ អនក្រ
# ស្តីពីការប្តូរឈ្មោះ ទីរួមខេត្ត សង្កាត់
# ក្នុងខេត្តកោះកុង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

www.pheakdeylaw.com